**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១. សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៨

### I. សេចក្តីផ្តើម

១- មាត្រា ២៦ ថ្មី នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ បានបែងចែកកិច្ចដំណើរការនៃការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាលទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែ មិនា ដល់ ខែ ឧសភា (២) *ដំណាក់កាលទី ២:* ការរៀបចំកញ្ចប់ថវិកា ពីខែ មិថុនា ដល់ ខែកញ្ញា និង *ដំណាក់កាលទី ៣:* ការអនុម័តថវិកា ពីខែ តុលា ដល់ ខែ ធ្នូ ។ ប្រការនេះ តំរូវអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសារាចរណែនាំពីរគឺ *សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា* ដែលត្រូវចេញនៅ ដើមខែ មេសា និង *សារាចរណែនាំស្តីពីការរៀបចំកញ្ចប់ថវិកា* ដែលត្រូវចេញនៅដើមខែ មិថុនា ។ ដូច្នេះ សារាចរនេះ មានគោលបំណងដើម្បីណែនាំ និង ធ្វើជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ឆ្នាំ ២០០៨ ដល់គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញគ្រប់ខេត្ត- ក្រុងទាំងអស់ ។

២- ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ជាពិសេស ដើម្បីបង្កើនការវិភាជន៍ថវិកាអោយចំទិសដៅ និង បំរើអោយសកម្មភាពអាទិភាពជាក់ស្តែងរបស់ក្រសួង- ស្ថាប័ន ក្នុងគោលដៅសំរេចអោយបាននូវគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួង- ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រជាអាទិភាពរបស់វិស័យនីមួយៗ ដើម្បីរួមចំណែកសំរេចអោយបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តំរូវអោយក្រសួង- ស្ថាប័ននីមួយៗ រៀបចំ និង ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** រៀងរាល់ឆ្នាំ ។ ផែនការយុទ្ធសាស្ត្រថវិកានេះគឺជាមូលដ្ឋានដ៏សំខាន់សំរាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតំរូវការថវិកា (៣) ជាមូលដ្ឋានសំរាប់ពន្យល់ និង ធ្វើអំណះអំណាងលើតំរូវការថវិកា និង ជាពិសេស (៤) គឺជាមូលដ្ឋានសំរាប់វាយតំលៃលើអាទិភាព ក្នុងការកំណត់កញ្ចប់ និង វិភាជន៍ថវិកា ។

៣- ដើម្បីអោយការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះអាចប្រព្រឹត្តទៅដោយរលូន និង គ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ តំរូវអោយផ្សាភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង បញ្ចូលទាំងចំណាយចរន្ត និង មូលធន ព្រមទាំងថវិកាជាតិ និង ថវិកាជំនួយផងនោះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតក្រុមការងារថវិកា ដែលមានសមាសភាពមកពី នាយកដ្ឋានហិរញ្ញវត្ថុ ឬ/និង គណនេយ្យ នាយកដ្ឋានផែនការ និង គ្រប់អង្គភាពគ្រប់គ្រងគំរោង ។ ហើយក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយផ្អែកលើគោលនយោបាយអាទិភាព របស់ក្រសួង និង វិស័យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នពិនិត្យ សំរេច និង ចុះហត្ថលេខា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបាន ***ត្រឹមថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧*** ដើម្បីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សំរាប់ពិនិត្យ និង អាចអញ្ជើញតំណាងក្រសួងសាម៉ីមកពិគ្រោះ និង សាកសួរពត៌មានបន្ថែមក្នុងករណីចាំបាច់ ។ ក្រសួង-ស្ថាប័ន ដែលផ្តល់ផែនការយុទ្ធសាស្ត្រថវិកាយឺត អាចធ្វើអោយប៉ះពាល់ដល់ការវិភាជន៍កញ្ចប់ថវិកាមិនបានសមស្របទៅនឹងអាទិភាពរបស់ខ្លួន ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៤- សេដ្ឋកិច្ចកម្ពុជា កំពុងតែវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការរីកធំធាត់ជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម នៅក្នុងរចនាសម្ព័ន្ធផលិតផលក្នុងស្រុកសរុប (ផសស) ។ ជាក់ស្តែង ក្នុងរយៈកាល ៧ ឆ្នាំ កន្លងទៅនេះ សមាមាត្រនៃវិស័យទាំង ៣ នៃសេដ្ឋកិច្ចកម្ពុជាបានវិវត្តពី វិស័យកសិកម្មរួមចំណែក ប្រមាណ ៣៦% វិស័យឧស្សាហកម្ម ២៧% និង វិស័យសេវាកម្ម ៣៧% នៅឆ្នាំ ២០០០ មកវិស័យកសិកម្ម រួមចំណែកត្រឹម ៣២% វិស័យឧស្សាហកម្ម ២៦% និង វិស័យសេវាកម្ម ៣៧% នៅឆ្នាំ ២០០៦ ។ ទោះបី សមាមាត្រនៃវិស័យកសិកម្មនៅក្នុង ផសស ចាប់ផ្តើមធ្លាក់ចុះជាបន្តបន្ទាប់ក៏ដោយ ក៏វិស័យនេះនៅតែ មានសក្តានុពលខ្ពស់ក្នុងការជំរុញ និង ពង្រីកកំណើនសេដ្ឋកិច្ច ក្នុងការជួយកាត់បន្ថយភាពក្រីក្រ នៅជនបទដែលជាអាទិភាពខ្ពស់នៅក្នុង យុទ្ធសាស្ត្រចតុកោណ ក៏ដូចជា ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ។ ប្រការនេះ បញ្ជាក់អោយឃើញថា ការបង្កើនទិន្នផល និង ផលិតភាពកសិកម្ម និង ការជំរុញការអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម ជាពិសេស កសិ-ឧស្សាហកម្ម សហគ្រាសធុនតូច និង មធ្យម ពាណិជ្ជកម្ម និងសេវាកម្ម គឺជាប្រការសំខាន់ដើម្បីបង្កើនតំលៃបន្ថែមលើផលិតផល និងស្រូបយកពលកម្ម ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស សំរាប់ស្រូបយកពលកម្មដែលត្រូវផ្ទេរចេញពី វិស័យកសិកម្ម ដើម្បីពង្រីកមូលដ្ឋាននៃកំណើន ស្ថិរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ច ។ កំណើនប្រជាជនសកម្មនៅក្នុងទីផ្សារពលកម្មមានប្រមាណ ៣០ ម៉ឺននាក់ ក្នុង ១ ឆ្នាំ ហើយវិស័យឧស្សាហកម្ម

និង សេវាកម្ម មិនទាន់អាចបង្កើតការងារធ្វើបានគ្រប់គ្រាន់នៅឡើយ ហេតុនេះ ការពង្រីកវិស័យកសិកម្ម នៅតែដើរតួសំខាន់ក្នុងការស្រូបយកកម្លាំងពលកម្ម ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលមធ្យម (២០០៨-២០១០) សេដ្ឋកិច្ចប្រាកដជាអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% ស្របតាម គោលដៅ យុទ្ធសាស្ត្រចតុកោណ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលមានមហិច្ឆិតានយោបាយដើម្បីសំរេចអោយបានកំណើនជាមធ្យមប្រមាណ ១០ % ។

៥- ឆ្នាំ ២០០៧ នេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានប្រមាណ ៨,៥% គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ (៦,៥%) តែទាបជាងការអនុវត្តន៍បានជាក់ស្តែង ក្នុងឆ្នាំ ២០០៦ (១០,៤%) កន្លងទៅ ។ នេះជាសេណារីយ៉ូប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ជាពិសេស ដោយសារការរងឥទ្ធិពលនៃការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន និង កត្តាឱនភាពថវិកា ឱនភាពគណនីចរន្ត និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ។ តាមសេណារីយ៉ូ នេះ វិស័យឧស្សាហកម្មនឹងមានកំណើនត្រឹមប្រមាណ ១០,៨% ធៀបនឹង ១៧% នៅក្នុងឆ្នាំ ២០០៦ (ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងមានកំណើនត្រឹមប្រមាណ ១២,៤% ធៀបនឹង ២១,៩% នៅក្នុងឆ្នាំ ២០០៦ ហើយផលិតផលសំណង់ នឹងមានកំណើនត្រឹមប្រមាណ ៩,៨% ធៀបនឹង ១៥,៧% នៅក្នុងឆ្នាំ ២០០៦) វិស័យសេវាកម្មនឹងមាន កំណើនប្រមាណ ៩,៥% ធៀបនឹង ១១,៤% នៅក្នុងឆ្នាំ ២០០៦ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍នឹងមានកំណើនប្រមាណ ១៣% ធៀបនឹង ១៧% នៅក្នុងឆ្នាំ ២០០៦) ។

៦- តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៨ ខាងមុខនេះ អាចនឹងសំរេចបាន ៧% ដោយសារវិស័យកសិកម្មនឹងកើនឡើង ៤% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនឡើងប្រមាណ ៤,៥% វិស័យឧស្សាហកម្មនឹងកើនឡើង ៨% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៩% និង ផលិតផលសំណង់នឹងកើនឡើង ៨% និង វិស័យសេវាកម្មនឹងកើនឡើង ៨,៤% ដែលក្នុងនោះ អាជីវកម្មទេសចរណ៍នឹងកើនឡើងប្រមាណ ១០% ។ អតិផរណានឹងស្ថិតនៅក្នុងកំរិតទាបប្រមាណ ៣% ហើយអត្រាប្តូរប្រាក់នឹងរក្សាបាននៅក្នុងរង្វង់ ៤ ១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ។

*ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

៧- ទោះជាឆ្នាំ ២០០៧ នេះ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានទាបជាងឆ្នាំ ២០០៦ ក៏ដោយ ក៏យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ពិសេស លើការអនុវត្តន៍ថវិកាឡើយ ព្រោះកំណើន ៨,៥% នេះ ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ (៦,៥%) ហើយការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និង ប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការអនុវត្តន៍កម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈជាជំហានៗ ប្រកប

ដោយភាពគ្រប់ជ្រុងជ្រោយ និង ទៅតាមលំដាប់លំដោយត្រឹមត្រូវនិងច្បាស់លាស់នោះ នឹងមិនត្រឹមតែធ្វើអោយការអនុវត្តន៍ថវិកាឆ្នាំ ២០០៧ សំរេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុប៉ុណ្ណោះទេ តែថែមទាំងអាចនឹងមានលក្ខណៈល្អប្រសើរជាងឆ្នាំ ២០០៦ ទៀតផង ។ តាមសេណារីយ៉ូនេះ ចំណូលជារួមនឹងកើនឡើងប្រមាណ ១៥% ធៀបនឹងការអនុវត្តន៍ឆ្នាំ ២០០៦ គឺចំណូលក្នុងស្រុកសរុបនឹងសំរេចបាន ១០,៥% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ៨,៧% នៃផសស (ចំណូលគយនិង រដ្ឋាករស្មើនឹង ៥,២% និង ចំណូលពន្ធដារស្មើនឹង ២,៧%) ចំណូលមិនមែនសារពើពន្ធនឹងសំរេចបាន ១,៧% នៃផសស ។ ចំណាយសរុបអាចនឹងសំរេចបាន ១៤,៣% នៃផសស កើនឡើង ២% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៨,៩% នៃផសស កើនឡើង ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៦ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៤% នៃផសស កើនឡើង ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ។ ការអនុវត្តន៍ចំណូល និង ចំណាយនេះ អាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ១,៥% និង ឱនភាពថវិកាសរុបប្រមាណ ៣,៨% នៃផសស ។

៨- ដោយឈរលើមូលដ្ឋាននៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល គួបផ្សំនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ថវិកាឆ្នាំ ២០០៨ មានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាការបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេស ការបន្តជំរុញការអនុវត្តន៍ យុទ្ធសាស្ត្រចតុកោណ *ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* របស់រាជរដ្ឋាភិបាល ដើម្បីសំរេចគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (PIP) ។
- ធានាបំរើអោយការរៀបចំបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងយន្តការលទ្ធិប្រជាធិបតេយ្យ ។
- បន្តបង្កើនបៀវត្សមូលដ្ឋានប្រមាណ ១៥% និង បន្តជំរុញការអនុវត្តន៍កន្សោមអាទិភាព
- ធានាការអនុវត្តន៍គោលនយោបាយអាទិភាពតាមវិស័យ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជា៖
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និង សុខាភិបាល ។
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍន៍ជនបទ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។
- ធានាការបន្តអនុវត្តកម្មវិធីកំណែទំរង់ និង អភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទំរង់ប្រព័ន្ធច្បាប់ និង តុលាការ កម្មវិធីកំណែទំរង់

ការគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិ កម្មវិធីកំណែទំរង់កងទ័ព កម្មវិធីកំណែទំរង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កម្មវិធីអភិវឌ្ឍន៍ផ្នែកឯកជន និង ការពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ។

៩- ដើម្បីធានាបាននូវការអនុវត្តន៍ទៅតាមគោលដៅទាំងអស់នេះ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០០៨ ត្រូវបានគ្រោងរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និង វិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តន៍អោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១១%នៃផសស គឺមានកំណើន ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសំរេចអោយបាន ៩,១% នៃផសស គឺមានកំណើន ០,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ១,៨% នៃផសស គឺមានកំណើន ០,១% ធៀបនឹងឆ្នាំ ២០០៧ និង ចំណូលមូលធនត្រូវសំរេចអោយបាន ០,៨% នៃផសស គឺប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ ។
- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស ពង្រឹងការរៀបចំថវិកាអោយកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និង សុក្រឹតភាព តាមរយៈការបន្តជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមអោយបានច្បាស់លាស់ និង សុក្រឹត ការធ្វើសមាហរណកម្មថវិកា និង ការអនុវត្តន៍ថវិកាកម្មវិធី ។ បន្តពង្រឹង និង ជំរុញការកែលំអការអនុវត្តន៍ថវិកា តាមរយៈការកាត់បន្ថយនីតិវិធីចំណាយ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការពង្រឹងការអនុវត្តន៍វិសហមជ្ឈការលទ្ធកម្មសាធារណៈ និង ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីសំរេចបានជាស្ថាពរនូវគោលដៅជំហានទី១ *គឺការបង្កើនភាពជឿទុកចិត្តបាននៃថវិកា* និង ចាប់ផ្តើមជំហានទី២ *គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ* តាមរយៈការបន្តពង្រឹងនិងបង្កើតការអនុវត្តន៍នូវប្លង់គណនេយ្យថ្មី និង មាតិកាថវិកាថ្មី អោយកាន់តែសុក្រឹត និង ឈានទៅសាកល្បងអនុវត្តប្រព័ន្ធពត៌មានវិទ្យាសំរាប់ការគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងក្របខ័ណ្ឌកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ។
- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអត្ថិសទិទ្ធរស់ថ្លៃ ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកំរិត ១៥,៣% នៃផសស ពីកើនឡើងប្រមាណ ១% នៃផសស ដែលក្នុងនោះ ចំណាយចរន្តនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ៩,៧% និង ចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៥,៦% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៣% នៃផសស និង ឱនភាពថវិកាសរុបក្នុងរង្វង់ ៤% នៃផសស ។
- បន្តផ្តល់អាទិភាព និង ជំរុញការរៀបចំថវិកាតាមកម្មវិធី និង ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាព

របស់រាជរដ្ឋាភិបាល ជាពិសេស បន្តពិនិត្យលទ្ធភាពដើម្បីបង្កើនការសាកល្បងការអនុវត្តន៍ថវិកាតាមកម្មវិធី តាមរយៈការបង្កើនទំហំថវិកាកម្មវិធី និង ពង្រីកការអនុវត្តន៍ទៅក្រសួងផ្សេងទៀតក្រៅពីក្រសួង ៧ ដែលបាននិងកំពុងអនុវត្តនៅក្នុងឆ្នាំ ២០០៧ នេះ (ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងកិច្ចការនារី) ។

- បន្តផ្តល់អាទិភាពលើកិច្ចការវិនិយោគសាធារណៈ ជាពិសេស លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវ ស្ពាន ប្រព័ន្ធស្រោចស្រព និង ការវិនិយោគលើការលើកកំពស់ផលិតភាពកសិកម្ម ។

III. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១០- ផែនការយុទ្ធសាស្ត្រថវិកា ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរួមមាន ២ ផ្នែកគឺ៖

***ផ្នែកទី ១*** គឺជាក្របខ័ណ្ឌគោលនយោបាយរបស់ក្រសួង (ច្រើនបំផុត ១០ សន្លឹក) ដែលបញ្ជាក់អំពី (១) តួនាទី និង មុខងាររបស់ក្រសួង (២) ទិសដៅគោលនយោបាយរយៈពេលមធ្យមរបស់ក្រសួង (២០០៨-២០១០) (៣) កម្មវិធីអាទិភាព ឬ/និង យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួងដើម្បីសំរេចបាននូវទិសដៅគោលនយោបាយរយៈពេលមធ្យម និង (៤) ប្រភពចំណូលសំរាប់បំពេញអោយការអនុវត្តន៍កម្មវិធីអាទិភាព ឬ/និង យុទ្ធសាស្ត្រអាទិភាព រួមទាំងបណ្តាវិធានការដើម្បីបង្កើនការប្រមូល ឬ/និង គៀងគរចំណូល ។

***ផ្នែកទី ២*** គឺជាតារាងគ្រោង និង ព្យាករណ៍ចំណូល-ចំណាយ ដែលរួមមាន (១) ការបែងចែកថវិកាទៅតាមកម្មវិធីអាទិភាព ឬ/និង យុទ្ធសាស្ត្រអាទិភាព និង ទៅតាមឆ្នាំនីមួយៗ សំរាប់រយៈពេល ៣ ឆ្នាំ (២) ការបែងចែកថវិការវាងចំណាយចរន្ត និង ចំណាយមូលធន ទៅតាមកម្មវិធីអាទិភាព ឬ/និង យុទ្ធសាស្ត្រអាទិភាព និង ទៅតាមឆ្នាំនីមួយៗ សំរាប់រយៈពេល ៣ ឆ្នាំ និង (៣) ការគ្រោង និង ព្យាករណ៍ចំណូលទៅតាមប្រភព និង ប្រភេទចំណូលនីមួយៗ សំរាប់រយៈពេល ៣ ឆ្នាំ ។

១១- ដើម្បីជាជំនួយ និង បង្កលក្ខណៈងាយស្រួលដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខាងក្រោមនេះ គឺជាបណ្តាជំហានដែលក្រសួង-ស្ថាប័នត្រូវយកទៅអនុវត្តតាម៖

***ជំហានទី ១៖ សង្ខេបតួនាទី និង មុខងាររបស់ក្រសួង*** តាមរយៈការពិពណ៌នាដោយខ្លីអំពីគោលបំណងរបស់ក្រសួង និង បញ្ជាក់ពីបណ្តាមុខងារទាំងនោះដែលនាំអោយសំរេចបាននូវគោលបំណងរបស់ក្រសួង ។

***ជំហានទី ២៖ កំណត់ទិសដៅគោលនយោបាយរយៈពេលមធ្យមរបស់ក្រសួង*** តាមរយៈការពិនិត្យ និង វិភាគទៅលើគោលបំណងរបស់ក្រសួង ហើយកំណត់ទិសដៅគោលនយោបាយអាទិភាព

រយៈពេលមធ្យម យ៉ាងច្រើន ៥ ដើម្បីសំរេចបាននូវគោលបំណងនោះ ។ គោលបំណង និង ទិសដៅទាំងនេះ ត្រូវតែស្ថិតនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយតាមវិស័យ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

*ជំហានទី ៣៖ កំណត់កម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង* តាមរយៈការ ការពិនិត្យ និង វិភាគទៅលើទិសដៅគោលនយោបាយរបស់ក្រសួង ហើយកំណត់កម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាពដើម្បីសំរេចបាននូវទិសដៅគោលនយោបាយនោះ ។

*ជំហានទី ៤៖ វិភាជន៍ធនធានថវិកាទៅតាមកម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាពរបស់ ក្រសួង* ដោយបញ្ចូលទាំងចំណាយចរន្ត និង មូលធន ព្រមទាំងថវិកាជាតិ និង ថវិកាជំនួយ សំរាប់ រយៈពេល ៣ ឆ្នាំ ដូចមានក្នុងតារាងគំរូភ្ជាប់មកជាមួយនេះ ។

១២- ទទួលសារាចរនេះហើយ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណី ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៧*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"*ដើម្បីជូនជ្រាប*"

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

"*ដើម្បីអនុវត្ត*"

- ឯកសារ-កាលប្បវត្តិ